ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមករា ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងខែមករា ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុទទួលរងឥទ្ធិពលពីជ្រលងសម្ពាធខ្ពស់បានថយចុះឥទ្ធិពល ផ្ទៃមេឃមានពពកតិចនិងខ្យល់បក់មកពីទិសឦសាន។ ជាមួយនោះ ប្រជាកសិករបានខិតខំជំរុញការងារប្រមូលផលដំណាំជាពិសេសដំណាំស្រូវរដូវវស្សានាពេលនេះប្រមូលផលបាន៩៦,៥៥% នៃផ្ទៃដីអនុវត្ត។ ទន្ទឹមនឹងនោះ ប្រជាកសិករបាននឹងកំពុងជំរុញដំណើរការការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៣-២០១៤ ក្នុងនោះដំណាំស្រូវសម្រេចបាន ១១០,៨១% នៃផែនការដាំដុះ។ ជារួមលទ្ធផលនៃការងារបង្កបង្កើនផលក៏ដូចជាសកម្មភាពតាមផ្នែកនីមួយៗកំពុងប្រព្រឹត្តទៅតាមទិសដៅដែលបានដាក់ចុះ។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

គិតមកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីសរុបចំនួន២.៤៧៥.៣៩៨ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៧.១៧៨.៩០៨តោន និងទិន្នផលជាមធ្យមចំនួន២,៩០០តោនក្នុងមួយហិកតា។

#### ១.២ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៤៨៥.៦៩០ហិកតា តិចជាងឆ្នាំមុនចំនួន២៨.១១២ហិកតា

-ផ្ទៃដីសាបសរុបចំនួន៤.៧៦៦ហិកតា តិចជាងឆ្នាំមុនចំនួន៥២៨ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤២៥.០០៧ហិកតា ស្មើនឹង១១០,៨១ភាគរយ នៃផែនការ៣៨៣.៥៣០ ហិកតា តិចជាងឆ្នាំមុនចំនួន៤៤.៨៩៣ហិកតា។

#### ១.៣ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៥៤.៥៦ហិកតា ស្មើនឹង១២៤,១៧ភាគរយ នៃផែនការសរុប៤៣.៩៤៤ហិកតា តិចជាងឆ្នាំមុន ៥១.២២៣ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន១៥.៥៥៩ហិកតា តិចជាងឆ្នាំមុន២៣.៩០៦ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន១៣.៨២៦ហិកតា តិចជាងឆ្នាំមុន១៤.៨៧៧ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន២.៣២៦ហិកតា តិចជាងឆ្នាំមុន៨៣៧ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន១៦.០៦៧ហិកតា តិចជាងឆ្នាំមុន៣.៩១៥ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន៦.៧៨៧ហិកតា តិចជាងឆ្នាំមុន៧.៦៨៨ហិកតា ។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

### ១.៤ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១០.៨៣៧ហិកតា ស្មើនឹង៥៤,០៧ភាគរយ នៃផែនការសរុប ២០.០៤៤ហិកតា តិចជាងឆ្នាំមុន ៤.២៧២ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន២.២៨៩ហិកតា លើសឆ្នាំមុន១២០ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន២៦ហិកតា តិចជាងឆ្នាំមុន២.៥៦៩ហិកតា

-ផ្ទៃដីល្ងចំនួន៩៨៥ហិកតា តិចជាងឆ្នាំមុន៥៥៩ហិកតា

-ផ្ទៃដីអំពៅចំនួន១.៧០១ហិកតា តិចជាងឆ្នាំមុន១.១១៧ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន៥.៨៣៦ហិកតា តិចជាងឆ្នាំមុន១០៧ហិកតា។

### ១.៥ ស្ថានភាពនៃការនាំចេញអង្ករក្នុងខែមករា ឆ្នាំ២០១៤

បរិមាណអង្ករនាំចេញក្នុងខែមករា ឆ្នាំ២០១៤នេះមានចំនួន២១.៥៣៦តោន មានការថយចុះចំនួន៤.១៩០តោន ឬ១៦,៣% តិចជាងខែមករា ឆ្នាំ២០១៣ដែលមានរហូតដល់២៥.៧២៦តោន។ គួរកត់សម្គាល់ថា ក្នុងរយៈពេល១២ខែ ឆ្នាំ២០១៣ បរិមាណនាំចេញអង្ករបានកើនដល់ចំនួន៣៧៨.៨៥៦តោន ដែលក្នុងរយៈពេល១២ខែ ឆ្នាំ២០១២ មានតែ ២០៥.៧១៧តោនប៉ុណ្ណោះ(មានកំណើន១៧៣.១៣៩តោន ឬ៨៤,១%) ដោយបាននាំចេញទៅកាន់ទិសដៅចំនួន៦៦ ប្រទេស។

## ២ ផ្នែកកៅស៊ូ

### ២.១ ការធ្វើអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៤៤,៣១ | ៥៧,៦៥ | ៥៤,០០ |
| | សរុប I | ៣៦៧,៧០ | ៣៤៤,៣១ | ៥៧,៦៥ | ៥៤,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុកគិរីកា អិនវេសមេន គ្រុប | ៨.២៧៣,៤៧ | ៦.៦៨៩,៤៤ | ៤.១៦៩,១៣ | ១.៤៧៦,០០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់ប៊ើលីមីធីត (តនគីរី) | ១.៥៣៩,៤៧ | ១.៦២៥,៩០ | ២១៦,៩៣ | ០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៨៦,៣៦ | ៨៨៥,០១ | ១៧៤,៩៣ | ១០០,៩០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ១.០២៤,៩០ | ៣.២៦៦,៩២ | ៣៥២,០៧ | ៣៤០,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩,០៨ | ១.៤៧០,៤៦ | ៦០២,៤០ |
| ៦ | ក្រុមហ៊ុន ស្ទឹហ្វីសេសស៍ (ស្នួល) | ១.៥៦១,៩០ | ២.៨២៤,៤១ | ៦៨២,៦០ | ៦៤០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.២៤៣,២៦ | ១.១៥៩,០០ | ១៣៩,២៣ | ៧៦,៦០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ២៦៧,១៦ | ១២៥,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | | ១.៥៧០,៦៣ | | |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ២.៦៣៤,៥៥ | ២.៦១៨,៧៥ | ៦១៤,៦៨ | ៥០៣,៤០ |
| | សរុប II | ២៣.៦៩៤,៥៨ | ២៩.៥៨៦,៦៧ | ៨.០៨៧,១៩ | ៣.៨៦៤,២០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រូសារ | ៥២.៥០៥,០០ | ៨៤.៩០១,០០ | | |
| | សរុប III | ៥២.៥០៥,០០ | ២២០.៣៤៧,០០ | | |
| | សរុប I+II+III | ៧៨.៥០៩,២៩ | ២៥០.២៧៧,៩៨ | ៨.១៤៤,៨៤ | ៣.៩១៨,២០ |

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-នៅក្នុងស្ថានីយមានជ្រូកសរុបចំនួន៣៨៣ក្បាល ក្នុងនោះជ្រូកបាចំនួន៨ក្បាល ជ្រូកបាបម្រុងចំនួន៤ក្បាល ជ្រូកមេទំនេរចំនួន៩៧ក្បាល ជ្រូកមេដើមចំនួន១៦ក្បាល មេជ្រូកបំបៅដោះចំនួន១៩ក្បាល កូនជ្រូកផ្តាច់ដោះចំនួន ៩៩ក្បាល កូនជ្រូកអាយុពី៧-៣០ថ្ងៃចំនួន៩១ក្បាល និងកូនជ្រូកអាយុពី០-៧ថ្ងៃចំនួន៤៩ក្បាល

-គោសរុបចំនួន២០៥ក្បាល ក្នុងនោះគោឈ្មោលចំនួន៥៥ក្បាល គោញីចំនួន១៥០ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន៩.៨០៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៦.៦១២ក្បាល ជំងឺប៉េស្តចំនួន១៤.១៧៤ក្បាល ជំងឺសាល់ម៉ូណែឡូសចំនួន៦.២៣៦ក្បាល ជំងឺអុតក្តាមចំនួន១.២០០ក្បាល ជំងឺអូហ្យេស្គីចំនួន១.២១១ក្បាល ជំងឺរាគកូនជ្រូកចំនួន ២.៩២៣ក្បាល ជំងឺកញ្ជ្រិលចំនួន៣៥៥ក្បាល ជំងឺជាតិដែកចំនួន១.១២០ក្បាល និងជំងឺផ្លូវដង្ហើមចំនួន៣៥៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១០.២៤២ក្បាល ជំងឺញ៉ូកាសចំនួន៣៧.៦៩៨ក្បាល ជំងឺប៉េស្តទាចំនួន ៨.០៥០ក្បាល និងជំងឺអាសន្នរោគចំនួន២២.០១១ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ធ្វើតេស្តពិនិត្យវត្ថុវិភាគសរុបចំនួន៧៦សំណាក

-ធ្វើកសិរវិរោគសាស្ត្រសរុបចំនួន០៣ក្បាល ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វដែលកំពុងប្រជុំពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីកម្រិតអន្តរក្រសួងចំនួន២លើក

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន០៤ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន១៩លើក កន្លែងចិញ្ចឹមមាន់ចំនួន៧១លើក កន្លែងចិញ្ចឹមទាចំនួន៦លើក កន្លែងលក់មាន់ចំនួន៨លើក ទ្រុងចិញ្ចឹមចំនួន១៤លើក បរិវេណភូមិចំនួន៨លើក សត្តឃាតដ្ឋានចំនួន២១លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៣.៥ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន១១១ឡ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន១.១៩២.៩៦០.០៩៥រៀល។

### ៤.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០១

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ៣.៧៩៣,០៨៥ម³ កូនឈើចំនួន២.៩៣៩ដើម អុសចម្រុះចំនួន១៤៥ស្ទែរ

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ ស្ថិតនៅក្នុងខេត្តចំនួន៤ មានសហគមន៍ព្រៃឈើចំនួន១៩កន្លែង និងគ្របដណ្តប់លើផ្ទៃដីសរុបចំនួន២១.០២៤,០៦ហិកតា។

### ៤.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអន្លង់ព្រីង តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប) ដែលមានសត្វស្លាបប្រមាណ១៩០ប្រភេទ (ប្រមាណ ២៦.៤២៩ក្បាល)

-រៀបចំអាហារដ្ឋានត្មាតចំនួន០៣លើក នៅតំបន់វាលបឹងទាល់នៃព្រៃការពារព្រះវិហារ និងនៅតំបន់ព្រៃការពារមណ្ឌលគិរី ដោយរាប់ឃើញត្មាតសរុបចំនួន១២៣ក្បាល

-ការពារសម្បុកសត្វត្រដក់តូចចំនួន៤០ ក្រយ៉ងចង្កំកសចំនួន១៨ និងត្មាតចំនួន១១ នៅតំបន់ព្រៃការពារព្រះវិហារ ព្រៃការពារមណ្ឌលគិរី និងតំបន់ទន្លេមេគង្គលើ

-បន្តថែរក្សាកូនក្រពើចំនួន២៧ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង អូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងតំបន់ស្មារក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំមានសត្វចំណូលថ្មីចំនួន៦១ក្បាល សត្វកើតថ្មីចំនួន៥ក្បាល សត្វដោះលែងចំនួន៥៨ក្បាល សត្វស្លាប់ចំនួន៧ក្បាល ព្យាបាលសត្វចំនួន១៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន៤ក្បាល ធ្វើឲ្យសន្លប់ចំនួន៩ក្បាល ទម្លាក់សត្វល្អិតចំនួន ២ក្បាល វះកាត់សាកសពសត្វចំនួន៣ក្បាល ដាក់លេខកូដចំនួន៥ក្បាល ចាក់វ៉ាក់សាំងចំនួន២២៨ក្បាល ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៤ម² ជួសជុលផ្លូវចំនួន២០.១០០ម² ថ្នាលអនាម័យព្រៃចំនួន៧១.០៩៦ម² បណ្តុះផ្កាលម្អ (ផ្កាក្រដាស)ចំនួន៥៤២ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១.១៤១នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ដាមមេ-បាពូជ និងកូនស្វាក្ដាមចំនួន៥៧.៥០០ក្បាល។

### ៤.៤ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

#### ៤.៤.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញចំនួន០៤ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០២ដែលមានបរិមាណឈើចំនួន៧.៦១៩,០៨៧ម³។

#### ៤.៤.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង៣៧សន្លឹក ដែលមានបរិមាណឈើចំនួន៤.៤៤៣,៧៧៤ម³។

### ៤.៥ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃដោយបញ្ជូនទៅតុលាការសរុបចំនួន ១៦០ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៥៩,៥៣៣ម³ ឈើអារចំនួន ២៥៤,០៤៧ម³ ឈើក្រាក់គ្រញូងចំនួន៤១,៣៧៧ម³ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប (គិតត្រឹមខែមករា ឆ្នាំ២០១៤)

-នេសាទដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន១៦.០០០តោន ស្មើ១០៦,៦៧% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨.០០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ សរុបបានចំនួន៥០.០០០តោន ស្មើ១២,៨២% នៃផែនការ ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ សរុបបានចំនួន២០.០០០តោន ស្មើ១១,១១% នៃផែនការ ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន ។

#### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣-២០១៤ (គិតត្រឹមខែមករា ឆ្នាំ២០១៤)

-អនុវត្តបានសរុបចំនួន៩.០០០តោន ស្មើ៨,១៨% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន។

### ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៧.០០០តោន ស្មើ៧%នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.៥០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន១០.០០០ក្បាល ស្មើ៣,៣៣% នៃផែនការ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួន៨.០០០.០០០កូន ស្មើ១០% នៃផែនការ១៦.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០.០០០កូន ។

### ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ សរុបបានចំនួន៨.០០០តោន ស្មើ៥,៣៣% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ សរុបបានចំនួន៩០០តោន ស្មើ១១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០តោន

-ការផលិតទឹកត្រី សរុបបានចំនួន៤.០០០.០០០លីត្រ ស្មើ៦,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ សរុបបានចំនួន១.២០០តោន ស្មើ៦% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន៨០០តោន ស្មើ៨% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន២១៩ករណី ដែលកើតមាននៅតំបន់ទឹកសាបមានចំនួន២១០ករណី និងតំបន់សមុទ្រ៩ករណី ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៩២ករណី គឺតំបន់ទឹកសាប១៨៥ករណីនិងតំបន់សមុទ្រ៧ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល សរុបបានចំនួន៥១១.៦៩០.០០០រៀល ស្មើ១៦,៨២% នៃផែនការ ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣៩៩.៩៤០.០០០រៀល។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាសរុបចំនួន៥៤៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន៣៩៨ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន១១០ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៦២៩ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន៥៦ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៣៨ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ ។ល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-បន្តត្រួតពិនិត្យ តាមដានការងារពិសោធន៍ស្រាវជ្រាវប្រមូលទិន្នន័យ

-ចុះប្រមូលព័ត៌មានអំពីការប៉ាន់ប្រមាណគម្រូវការនៃការដាំដុះ និងការកែច្នៃដំណាំដំឡូងមី

-ចុះដាំពូជស្រូវជលសារបង្ហាញដោយម៉ាស៊ីនដាំអូសនឹងគោយន្ត ព្រមទាំងប្រមូលព័ត៌មាននិងសាកល្បងបញ្ជីសំនួរពីការដាំដុះដំណាំដំឡូងមី

-ទទួលគណៈប្រតិភូអន្តរក្រសួងនៃប្រទេសបង់ក្លាដេសចំនួន៦រូប ដែលដឹកនាំដោយ Mr. Md. Hemayet Uddin Deputty Secretary នៃក្រសួងកសិកម្មប្រទេសបង់ក្លាដេស ដើម្បីពិភាក្សាការងារស្តីពីផលិតភាពដំណាំកសិកម្មនៅក្នុងប្រទេសកម្ពុជា។

## ៨ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៨.១ សាលាជាតិកសិកម្មព្រែកលៀប

**និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥៦២នាក់(ស្រី៥០២នាក់)ក្នុងនោះ៖**

-និស្សិតអាហារូបករណ៍(ទូទៅ)ចំនួន១.០៥០នាក់ ក្នុងនោះស្រី៣៨៣នាក់ (ថ្នាក់បរិញ្ញា៨១៣នាក់ និងថ្នាក់បរិញ្ញារង២៣៧នាក់)

-និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ (ថ្នាក់បរិញ្ញា១៥៤នាក់ និងថ្នាក់បរិញ្ញារង៤២នាក់)

-និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៦១នាក់ ក្នុងនោះស្រី៣៧នាក់ (ថ្នាក់បរិញ្ញា១៤២នាក់ និងថ្នាក់បរិញ្ញារង១៩នាក់)។

### ៨.២ សាលាជាតិកសិកម្មកំពង់ចាម

**និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ៨.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៥៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា០៩មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៣គិតមកទល់ពេលនេះ ប្រជាកសិករបាននឹងកំពុងខិតខំជំរុញការងារប្រមូលផលដំណាំរដូវវស្សានឹងឈានជិតដល់បញ្ចប់។ ទន្ទឹមនឹងនោះ ការងារបង្កបង្កើនផលដំណាំនារដូវប្រាំងជាពិសេសដំណាំស្រូវសម្រេចបានលើសផែនការ ហើយនឹងឈានជិតបញ្ចប់ការដាំដុះដែរ។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវក៏ដូចជាការថែទាំដំណាំផ្សេងៗនិងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ព្រមទាំងរក្សាទឹកទុកឲ្យបានគត់មត់នៅចុងរដូវ។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទតឹងតែង ស្មិតស្មាញ ហើយដែលត្រូវតែខិតខំបន្តសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។

## V- ទិសដៅ

-បន្តតាមដានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ និងវាយតម្លៃទិន្នផល និងបរិមាណផលទទួលបានឲ្យបានច្បាស់លាស់

-សហការជាមួយអាជ្ញាធរដែនដីធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាកសិករឲ្យយកចិត្តទុកដាក់ជំរុញការងារមុនប្រមូលផល និងក្រោយពេលប្រមូលផលស្រូវ ដោយត្រូវប្រមូលផ្ដុំរក្សាទុកដាក់ក្នុងជង្រុកឱ្យបានល្អតាមបច្ចេកទេសដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារផង និងការលៃទុកពូជផង

-តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវប្រាំង ដើម្បីណែនាំជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរមូលដ្ឋាន សម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង និងចាំបាច់។ សម្រាប់ស្រូវរដូវប្រាំងត្រូវបន្តផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ ជាពិសេសពូជ IR 66 ពូជផលសារ។ល។

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតចង្រៃ និងតាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអត្ថិភាពស្បៀង (អង្ករ) ដោយ ជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវវស្សា ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយដល់ប្រជាកសិករដែលធ្វើស្រូវចម្ការឱ្យប្តូរពូជស្រូវដើម្បីបង្កើនទិន្នផលនិងយកចិត្តទុកដាក់ជំរុញការប្រុងប្រយ័ត្នបង្ការភ្លើងឆេះស្រូវដោយចៃដន្យក្នុងរដូវប្រាំងនេះ

-ពិនិត្យ និងពង្រឹងឡើងវិញនូវមធ្យោបាយនិងសម្ភារៈផ្សេងៗដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍មានដូចជា ៖ ស្រូវពូជនិងពូជបន្លែ មធ្យោបាយនានាសម្រាប់អន្តរាគមន៍ដល់គ្រោះរាំងស្ងួត (អន្តរាគមន៍បូមបាច) និងមធ្យោបាយសម្ភារៈនានាដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូនិងចុះពិនិត្យនៅតាមបណ្ដាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-បន្តជំរុញការថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់ និងត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្ដាសាយបក្សី និងជំងឺផ្ដាសាយ (A)H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្តពិសេសការចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ

-បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ស្ដីពីព្រៃឈើ បទបញ្ជាលេខ០១-០២សជណនិងអនុសាសន៍សម្ដេចតេជោនាយករដ្ឋមន្ត្រី

-បន្តជំរុញដាក់ដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមអំណាចសាលក្រមតុលាការនិងពិន័យអន្តរការណ៍ដើម្បីកុំឲ្យឈើបាត់បង់គុណភាពនិងតម្លៃ

-បន្តជំរុញពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយផ្ដល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចម្ការព្រៃដាំ ដែលផ្ដល់ផលប្រយោជន៍ច្រើនយ៉ាង តាមរយៈការបង្កើនដាំដុះព្រៃឈើ

-បន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានាអនុវត្តគម្រោងការបណ្ដុះបណ្ដាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធតាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃនិងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍ដែលមានស្រាប់និងស្វែងរកដៃគូថ្មីៗទៀត

-បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្ដារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មនិងថែរក្សាការពារចម្ការព្រៃពូជនិងប្រមូលគ្រាប់ពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ជាពិសេសប្រព័ន្ធព័ត៌មានព្រះរាជអាជ្ញាស្ថាប័នតុលាការក្នុងការគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល និងរៀបចំពង្រឹងសង្កាត់រដ្ឋបាលជលផលគ្មានបទល្មើស

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-រៀបចំបោះបង្គោលបេតុងចំនួន៤១បង្គោល និងសាងសង់ស្នាក់ការល្បាតចំនួន១០កន្លែងនៅកន្លែងអភិរក្សជលផលក្នុងនោះស្នាក់ការបណ្ដែតទឹក០៥កន្លែង

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យក្លាយជាសហគមន៍គ្មានបទល្មើស

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យ ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើតនិងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់ដល់ធនធានជលផល

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការអនុវត្តអនុសាសន៍ប្រកបដោយគតិបណ្ឌិតរបស់ តេជោសែន អំពីការដំឡើងកាំប្រាក់មន្ត្រីរាជការឲ្យបានលឿនដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការឲ្យខិតខំប្រឹងប្រែងធ្វើការប្រកបដោយប្រសិទ្ធភាព

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ ក្នុងវិស័យកសិកម្មឲ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន